# រឿង ចៅតប់ប្រមល់



០៨០.
១១១

Khmer Picture Book No.37
An unhappy man
Donated by Rissho-Kosei Kai(RKK)

ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរ ដោយរូបភាព សំរាប់កុមារ លេខ ៣៧
និពន្ធ និងរៀបរៀងដោយគណៈកម្មការរបស់ក្រសួងអប់រំយុវជន និងកីឡា,
សមាគមអ្នកនិពន្ធខ្មែរ និងបណ្ណាល័យអង្គការ JSRC

| | |
|---|---|
| លោក ណាត ប៊ុនរឿន | ប្រធានក្តាប់រូម |
| លោក ឆាយ ផល្លី | អ្នកសំរបសំរួល |

**គណៈកម្មការត្រួតពិនិត្យ**

| | |
|---|---|
| ១. លោក មួង ចាន់ទូច | ប្រធាន |
| ២. អ្នកស្រី ជិន យ៉ាហន | សមាជិកា |
| ៣. អ្នកស្រី ឱម ធីរិទ្ធ | សមាជិកា |

**គណៈកម្មការនិពន្ធ និងរៀបរៀង**

| | |
|---|---|
| ១. លោក យូ បូ | ប្រធាន |
| ២. លោក វ៉ា សំអាត | សមាជិក |
| ៣. អ្នកស្រី យឹម នីម៉ូល្លា | សមាជិកា |

វិចិត្ររូបភាពដោយ គាំ សារ៉ែន

ឧបត្ថម្ភដោយបណ្ណាល័យអង្គការ JSRC
បោះពុម្ពដោយរោងពុម្ពអង្គការ JSRC ចំនួន ៣០០០ ច្បាប់
បោះពុម្ព ខែ សីហា ឆ្នាំ១៩៩៧
សៀវភៅនេះ បានទទួលការអនុញ្ញាតអោយបោះពុម្ពពីក្រសួងពត៌មាន
លេខ ១៩១/៩៦ ម. ព. ប្រ. ក ចុះថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ១៩៩៦
រក្សាសិទ្ធិ ដោយអង្គការជំនួយសូតូស៊ូ ជប៉ុន ( JSRC )

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។


សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។


Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.


A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh      www.elibraryofcambodia.org

០៤០.១១១

# បុព្វកថា

***៙***

ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារ នេះ បានរៀបរៀងឡើងក្នុងគោលបំនង:

- ធ្វើអោយកុមារមានសេចក្ដីសប្បាយរីករាយ
- ជួយដល់ការលូតលាស់ផ្នែកស្មារតី និងអប់រំបញ្ញារបស់កុមារ
- អោយកុមារស្គាល់វប្បធម៌របស់ខ្មែរ
- ជំនួយដល់ឪពុកម្ដាយ រឺ លោកគ្រូ អ្នកគ្រូ ក្នុងការនិទានរឿងផ្សេងៗ សំរាប់កុមារ

យើងខ្ញុំរង់ចាំទទួលនូវការផ្ដល់មតិកែលំអ ពីមិត្តអ្នកអានទាំងអស់ ដោយសេចក្ដីសោមនស្សរីករាយជាទីបំផុត ។

សូមអរគុណ !

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៤០៩៤/៩៨



កាលពីព្រេងនាយ មានបុរសពីរនាក់បានសាងកុសលជាមួយគ្នា ។ លុះបុរសទាំងពីរស្លាប់ទៅ បុរសម្នាក់បានកើតទៅជាព្រះឥន្ទ្រ បុរសម្នាក់ទៀតទៅកើតជាបុរសកំសត់ មានប្រពន្ធក្រលំបាកណាស់ រកស៊ីនេសាទដាក់លបយកត្រីជារបរចិញ្ចឹមជីវិត ។





គ្រាមួយ ព្រះឥន្ទ្របានបើកព្រះនេត្រទិព្វមក ឃើញបុរសនោះលំបាកវេទនាយ៉ាងដូចនេះ មាន សេចក្ដីអានិតអាសូរយ៉ាងខ្លាំង ។ វេលាយប់ ព្រះឥន្ទ្រ យកមាសបីដុំទៅដាក់ក្នុងលបបុរសនោះ ។ លុះព្រឹក ឡើងបុរសនោះទៅលើកលប ឃើញមាស មិនស្គាល់ ជាមាសសំគាល់ថាជាថ្ម ក៏ចោលទៅក្នុងទឹក ហើយ ដាក់លបទៅក្នុងទឹកវិញ ។





បុរសបានមកមើលលបទៀត គំរប់បីដង ។ ព្រះឥន្ទ្រយកមាសដាក់ក្នុងលបដូចមុនទៀត ។ បុរសឃើញដូចនោះ នឹកខឹងក៏ចងមាសបីដុំនោះ ពុនយកទៅធ្វើជាថ្មជើងក្រានដាំបាយ ។ ប្រពន្ធបុរសមិនស្គាល់មាស ក៏យកដុំមាសនោះទៅធ្វើជាថ្មជើងក្រានតាមបង្គាប់ប្ដី ។



ក្រោយនោះ មានព្រះរាជអាជ្ញាមកទារពន្ធ ។ គាត់មើលឃើញដុំមាស ដែលបុរសនោះធ្វើជាថ្មជើងក្រាន ក៏អោយបុរសយកមាសទាំងបីដុំនោះ មកបង់ពន្ធដែលជំពាក់រាជការ ។ បុរសនឹកអរណាស់ ក៏ព្រមប្រគល់ថ្មជើងក្រានទាំងបីដុំនោះ ទៅអោយព្រះរាជអាជ្ញាភ្លាម ។



លុះព្រះរាជអាជ្ញាបានដុំមាសពីបុរសនោះហើយក៏
យកមួយដុំទៅថ្វាយព្រះមហាក្សត្រ ។ ព្រះអង្គទ្រង់
សាកសួរពីហេតុដែលបានមាសមកនោះ ព្រះរាជ
អាជ្ញាក៏ទូលតាមដំណើរ ។





ស្ដេចទ្រង់ជ្រាបដូចនេះ ទ្រង់អោយហៅបុរសនោះទៅសាកសួរ ។ បុរសក្រាបទូលថា «មាសរបស់ទូលព្រះបង្គំបីដុំ បានជូនមកព្រះរាជអាជ្ញាហើយ» ។ ស្ដេចអោយទារយកមាសពីរដុំទៀត ពីព្រះរាជអាជ្ញានោះ ហើយទ្រង់បង្គាប់អោយបុរសនោះ រកមាសមកថ្វាយព្រះអង្គថែមទៀត ។ បុរសនោះក្រាបទូលថា «រកមាសពុំបានទៀតទេ » ។



ស្ដេចទ្រង់អោយយកបុរសនោះ ទៅឃុំ ។ ព្រឹកឡើង នាយតំរួតប្រើបុរសនោះអោយធ្វើការ ដោយមានការជេរស្ដីផង ។



លុះជ្រាបដល់ស្ដេច ស្ដេចទ្រង់អោយហៅបុរសនោះ មកសួរពីហេតុដែលធ្វើអោយមានការទាស់ចិត្តនាយតំរួត ។ បុរសនោះក្រាបទូលថា «ទូលព្រះបង្គំមានសេចក្ដីតប់ប្រមល់នៅក្នុងខ្លួនខ្លាំងណាស់» ។ ស្ដេចក៏មានព្រះបន្ទូលថា «បើដូចនេះ ត្រូវចៅឯងរកសត្វតប់ប្រមល់នោះមកអោយអញ បើឯងរកពុំបានទេ អញនឹងអោយគេសំលាប់ឯងក្នុងគ្រានេះ» ។ បុរសលីដូចនោះក៏ភ័យ គិតថា «មុខជាស្លាប់ហើយគ្រានេះ មិនដឹងជាទៅរកសត្វតប់ប្រមល់ឯណាទេ» ។ តែមិនហ៊ានប្រកែកដោយខ្លាចអំណាចស្ដេច ក៏ក្រាបបង្គំលាស្ដេចដើរចេញទៅដោយបំនងថា នឹងដើរអោយស្លាប់ក្នុងព្រៃ ។





លុះដើរចូលព្រៃឆ្ងាយទៅ ព្រះឥន្ទ្របើកព្រះនេត្រទិព្វមកឃើញបុរសនោះមានសេចក្ដីវេទនាលំបាកដូចនោះ ក៏និម្មិតជាអាស្រមមួយនៅខាងមុខទីដែលបុរសដើរទៅ ហើយព្រះអង្គកាលាខ្លួនធ្វើជាព្រះមហាឥសី។





បុរសមើលទៅឃើញអាស្រមដូចនោះ ក៏មានចិត្តត្រេកអរដើរចូលទៅថ្វាយបង្គំឥសីក្នុងអាស្រមនោះ ។ ឥសីសួរថា «ចៅមានហេតុអ្វី ? » ។ បុរសនោះទូលឥសីតាមដំណើរដែលស្តេចអោយរកសត្វតប់ប្រមល់យកទៅថ្វាយ ។ ឥសីថា «ចៅកុំព្រួយ » រួចឥសីបានយកបំពង់ពកមួយមកសែកមន្តវិជ្ជាសិល្បសាស្ត្រ កើតជាខ្លា សិង្ហ ដំរី ពស់ រមាស សុទ្ធតែជាសត្វសាហាវទាំងអស់ ហើយឥសីសែកជប់បង្រួញសត្វទាំងនោះច្រកក្នុងបំពង់ពក ប្រគល់បំពង់ពកនោះ អោយទៅបុរស រួចផ្តាំថាអោយយកទៅថ្វាយស្តេច ប៉ុន្តែមុននឹងបើកឆ្នុក អោយស្តេចប្រមូលរាជវង្សានុវង្សមកជួបជុំ ហើយបិទទ្វាររាំងអោយជិត សឹមបើកឆ្នុកមើល ព្រោះសត្វនោះរត់រហ័សណាស់ ។



លុះបុរសនោះទទួលបណ្ដាំឥសីស្រេចហើយ ក៏នាំយកសត្វដែលច្រកក្នុងបំពង់ពកទៅថ្វាយស្ដេច ដោយក្រាបទូលថា « ទូលព្រះបង្គំរកសត្វតប់ប្រមល់បានហើយ នៅក្នុងបំពង់នេះ » ហើយក៏ទូលតាមដំណើរដែលឥសីផ្ដាំមក ។ ស្ដេចអោយប្រមូលរាជវង្សានុវង្សមកជួបជុំ រួចទ្រង់ចាត់ការបិទទ្វារវាំង ទ្រង់អោយអាមាត្យបើកឆ្នុកបំពង់ពកនោះ ។ ខ្លា ដំរី សិង្ហ រមាសពស់ ក៏ចេញពីបំពង់ពកមកខាំស្ដេច និងព្រះរាជវង្សានុវង្សនោះ ដល់នូវមរណភាពអស់ទៅ ។



ក្រោយមក ពួកអ្នកនគរឃើញបុរសមានរិទ្ធានុភាពដូចនេះ ក៏រៀបអភិសេកបុរសនោះអោយឡើងសោយរាជសម្បត្តិជាព្រះមហាក្សត្រក្នុងនគរនោះទៅ។ សត្វទាំងឡាយក៏លាព្រះរាជាអង្គនោះ ចូលទៅនៅព្រៃវិញ ហើយផ្ដាំថា « បើព្រះអង្គមានភ័យ រឺមានការអ្វីគ្រាន់តែនឹកដល់ ពួកយើងនឹងមកជួយយកអាសារជាដរាប » ៕

